ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧២ . សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការបង្ក្រាបបទល្មើសនានា និង ត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ
- បានឃើញសេចក្តីប្រកាសលេខ ០២ ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យជលផល
- បានឃើញសេចក្តីសំរេចលេខ ១៨ សសរ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីទប់ស្កាត់បទល្មើសអនាធិបតេយ្យក្នុងវិស័យជលផលនៃដែនសមុទ្រកម្ពុជា
- យោងតាមសំណូមពររបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកោះកុង

## សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ ដើម្បីបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃ ដូចមានសមាសភាពខាងក្រោម :

www.pheakdeylaw.com

| | | |
|---|---|---|
| -ឯកឧត្តម | ប៊ុន លើត អភិបាលនៃគណៈអភិបាលខេត្តកោះកុង | ប្រធាន |
| -ឯកឧត្តម | លី យ៉ុងផាត់ ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី | អនុប្រធាន |
| -ឯកឧត្តម | កែវ សាមួន មេបញ្ជាការយោធភូមិភាគទី ៣ | អនុប្រធាន |
| -លោកឧត្តមនាវីត្រី | ទៀ សុខា មេបញ្ជាការរងមូលដ្ឋានសមុទ្រ | អនុប្រធាន |
| -លោក | ពុំ ស៊ីថា ប្រធានស្នាក់ការជលផលដែនសមុទ្រ | សមាជិក |
| -លោកមេបញ្ជាការស្រោលប្រចាំសមុទ្ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិ | | សមាជិក |
| -លោកមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង | | សមាជិក |
| -លោកមេបញ្ជាការកងរាជអាវុធហត្ថខេត្តកោះកុង | | សមាជិក |
| -លោកស្នងការនគរបាលខេត្តកោះកុង | | សមាជិក |
| -លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង | | សមាជិក |
| -លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកោះកុង | | សមាជិក |
| -លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង | | សមាជិក |
| -លោកប្រធានមន្ទីរពាណិជ្ជកម្មខេត្តកោះកុង | | សមាជិក |
| -លោកប្រធានសាខាគយ និងរដ្ឋាករខេត្តកោះកុង | | សមាជិក |
| -លោកប្រធានសាខាកាំកុងត្រួលប្រចាំខេត្តកោះកុង | | សមាជិក |

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

-បង្ក្រាបការធ្វើនេសាទអនាធិបតេយ្យ និងការពារការធ្វើនេសាទស្របច្បាប់របស់ប្រជាពលរដ្ឋ

-បង្ក្រាបការដឹកជញ្ជូនផល អនុផលព្រៃឈើ និងឈើកែច្នៃគ្រប់ប្រភេទដែលគ្មានច្បាប់អនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-បង្ក្រាបការដឹកជញ្ជូនទំនិញរត់គេចពន្ធ គ្រឿងញៀន និងបទល្មើសនានា

-រកឱ្យឃើញ និងលើកសំណើ ដើម្បីមានវិធានការដាក់វិន័យយ៉ាងតឹងរឹងចំពោះក្រុម ឬជនខិលខូចដែលបង្ខំទារប្រាក់ពីអ្នកធ្វើអាជីវកម្មស្របច្បាប់ដែលបានបង់ពន្ធ និងអាករផ្សេងៗជូនរដ្ឋរួចហើយ

-ធ្វើការបែងចែកប្រភេទ និងគ្រប់គ្រងយានយន្ត ជលយានយន្ត ដែលធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ ទំនិញ និងនេសាទ ហើយនិងយានយន្ត ជលយានយន្ត ដែលប្រើប្រាស់ផ្ទាល់របស់ប្រជាពលរដ្ឋក្នុងដែនដី និងដែនសមុទ្រខេត្តកោះកុង

-សហការ និងធ្វើទំនាក់ទំនងជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសថៃ ស្តីពីការគ្រប់គ្រងលើការធ្វើអាជីវកម្មនេសាទ និងបញ្ហាពាក់ព័ន្ធផ្សេងទៀតលើដែនសមុទ្រកម្ពុជា-ថៃ និងក្នុងតំបន់ត្រួតគ្នានៃសមុទ្ររវាងកម្ពុជា-ថៃ

-ពិភាក្សាដោះស្រាយទំនាស់នានាជាមួយភាគីថៃ ដោយមិត្តភាព និងសន្តិវិធី

www.pheakdeylaw.com

-អនុវត្តភារកិច្ចផ្សេងទៀតដែលប្រមុខរាជរដ្ឋាភិបាលប្រគល់អោយ

-រាយការណ៍អំពីលទ្ធផលការងារតាមករណីជាក់ស្តែងនីមួយៗ និងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់គណៈកម្មការនេះប្រចាំខែអោយបានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល ព្រមទាំងចម្លងជូនក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងពាក់ព័ន្ធផ្សេងទៀត ។

ប្រការ ៣ : គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់មធ្យោបាយ និងកំលាំងរបស់គណៈបញ្ជាការឯកភាពខេត្ត កងនាវាចរដែនសមុទ្រកងទ័ពជើងទឹកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលការពារព្រំដែនទឹកនៃអគ្គនាយកដ្ឋាននគរបាលជាតិដែលមានស្រាប់នៅនឹងកន្លែង ។

កំលាំងដែលធ្វើសកម្មភាពបង្ក្រាបបទល្មើសត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់ពីប្រធានគណៈកម្មការ និងស្ថិតក្នុងរង្វង់ដែនសមុទ្រនៃខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃ ។

ចំពោះបទល្មើសដែលចាប់ឃាត់បាន គឺអាស្រ័យដោយសមត្ថកិច្ចជំនាញសាមីនីមួយៗជាអ្នករៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

ប្រការ ៤ : គណៈកម្មការនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយដែលមានអនុប្រធានគណៈកម្មការ ០១រូប ជាប្រធាន សំរាប់ជំនួយការងារជាអចិន្ត្រៃយ៍ ដែលមានទីស្នាក់ការកណ្តាលនៅសាលាខេត្តកោះកុង និងមានសាខាទីស្នាក់ការនៅកោះស្តេច និងកោះតាងសំរាប់ជំនួយការក្នុងការផ្តល់ព័ត៌មាន និងទទួលបទបញ្ជាផ្សេងៗពីទីស្នាក់ការកណ្តាល ។

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តកោះកុង ។

ប្រការ ៥ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃស្ថាប័ន ដែលមានការពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោកដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com